雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.150

ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7605 ថ្ងៃសុក្រ ទី06 ខែ មេសា ឆ្នាំ 2018

គម្រោងដំណាក់កាលទី១ នៃខ្សែរថភ្លើងចិន-ថៃកំពុងដំណើរការសាងសង់ដោយរលូន

"FUXING" CR400AF EMU

គំរូរថភ្លើងល្បឿនលឿន របស់ចិនត្រូវបានតាំងបង្ហាញនៅ ក្នុងកម្មវិធី ពិព័រណ៍ផ្លូវដែកអាស៊ី និង វេទិកាស្តីអំពីកំណើនឆ្នាំ ២០១៨ ដែលបានរៀបចំឡើងនៅប្រទេសថៃ កាល ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែមីនា (រូបថត ដោយស៊ីនហួ)

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១៨ លោកថានីង សុងវិន ប្រធាននាយកដ្ឋានគ្រប់គ្រង ផ្លូវថ្នល់នៃក្រសួងគមនាគមន៍ថៃបានថ្លែងសុន្ទរកថា ក្នុងការដ្ឋានសាងសង់ខ្សែរថភ្លើងចិន-ថៃ នៅខេត្តនគររាជសីមានៃប្រទេសថៃ ថា សព្វថ្ងៃគម្រោងដំណាក់កាលទី១នៃខ្សែរថភ្លើងចិន-ថៃកំពុងដំណើរការសាងសង់ដោយរលូន ចំណែកបទពិសោធន៍ដែលទទួលបានក្នុងការអនុវត្តគម្រោងសាងសង់ដំណាក់កាលទី១ នេះនឹងអាចត្រូវបានប្រើប្រាស់ក្នុងការសាងសង់កំណាត់ផ្លូវដែកផ្សេងៗទៀត ។

លោកបានបញ្ជាក់ថា ភាគីចិនទទួលខុសត្រូវចំពោះការគូរប្លង់ ឌីហ្សាញនូវគម្រោងសាងសង់ខ្សែរថភ្លើងនេះចំណែកនាយកដ្ឋានគ្រប់គ្រងផ្លូវថ្នល់នៃក្រសួងគមនាគមន៍ថៃទទួលខុសត្រូវចំពោះការសាងសង់គ្រឹះផ្លូវដែក ។ បន្ទាប់ពីនោះភាគីចិននឹងទទួលបន្ទុកក្រាលផ្លូវដែកនិងការងារពាក់ព័ន្ធផ្សេងៗទៀត ។ លោកបន្តទៀតថា ភាគីចិននិងថៃបានបង្កើតកិច្ចសហប្រតិបត្តិការយ៉ាងស្អិតល្មួតក្នុងការអនុវត្តគម្រោងសាងសង់ផ្លូវដែកដំណាក់កាលទី១ ចំណែកបទពិសោធន៍ដែលទទួលបានក្នុងការអនុវត្តគម្រោង ដំណាក់កាលទី១ នឹងអាចត្រូវបានប្រើប្រាស់ក្នុងការអនុវត្តគម្រោងសាងសង់នាពេលខាងមុខ ។

វិស្វករប្រចាំការនៃប្រទេសថៃបានលើកមតិថាគម្រោងដែលប្រទេសចិននិងថៃរួមសហការគ្នាក្នុងការសាងសង់ផ្លូវដែកនេះគឺជាឱកាស ដ៏ល្អមួយសម្រាប់ឱ្យប្រទេសថៃរៀនបទពិសោធន៍ពីប្រទេសចិន ។ គ្រឿងបរិក្ខារមួយចំនួនត្រូវនាំចូលពីប្រទេសចិន ។ តាមការឧទ្ទេសនាមបានឱ្យដឹងថា ភាគីចិនទទួលខុសត្រូវចំពោះការគូរប្លង់ឌីហ្សាញពិនិត្យគុណភាពនៃការសាងសង់ដំឡើងប្រព័ន្ធបញ្ជូនសេវានិងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីផលិតនិងផ្តល់រថភ្លើង ព្រមទាំងការរៀបចំការបណ្តុះបណ្តាលដល់អ្នកបច្ចេកទេសថៃជាដើម។

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៧ គម្រោងដំណាក់កាលទី ១(បាងកក-នគររាជសីមា)នៃខ្សែរថភ្លើងចិន-ថៃបានបើកការដ្ឋានសាងសង់ជាផ្លូវការនៅប្រទេសថៃ ។ គម្រោងសាងសង់ខ្សែរថភ្លើងដំណាក់កាលទី១ នេះមានប្រវែងសរុប ២៥៣គីឡូម៉ែត្រ ដែលមានចំណតចំនួន៦ ។ រថភ្លើងអាចធ្វើដំណើរក្នុងល្បឿន២៥០គីឡូម៉ែត្រ/ម៉ោង តាមខ្សែរថភ្លើងនេះ ។ គួរបញ្ជាក់ថា ខ្សែរថភ្លើងនេះបានប្រើប្រាស់បច្ចេកទេសរបស់ប្រទេសចិនហើយជាផ្លូវដែកល្បឿនលឿនទី ១របស់ប្រទេសថៃ ។

ដោយយ៉ាង ចូវ(ស៊ីនហួចិន)

ចិននិងវៀតណាមបើកច្រកអន្តរជាតិផ្លូវគោកថ្មី

នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០១៨ ប្រទេសចិននិងវៀតណាមបានរួមគ្នារៀបចំពិធីបើកច្រកអន្តរជាតិទូឡុងប្រទេសចិន-ជីងមិនខូវប្រទេសវៀតណាម។ នេះគឺជាច្រកអន្តរជាតិផ្លូវគោកថ្មីមួយទៀតរវាងប្រទេសចិននិងវៀតណាមសម្រាប់ឱ្យអ្នកដំណើរឆ្លងដែន និងដឹកជញ្ជូនទំនិញតាមផ្លូវគោក។

ច្រកអន្តរជាតិទូឡុងប្រទេសចិនមានទីតាំងស្ថិតនៅតាមបង្គោលព្រំដែនចិន-វៀតណាមលេខ១៩៧ ដែលមានចម្ងាយ៤៧គីឡូម៉ែត្រពីទីរួមស្រុកម៉ាក្វាន់នៃមណ្ឌលស្វយ័តជនជាតិជ្វួង និងមាវ វិនសាន ខេត្តយូនណាន។ ច្រកអន្តរជាតិនេះជាច្រកផ្លូវគោកដ៏សំខាន់សម្រាប់ធ្វើដំណើរពីខេត្តយូនណានទៅប្រទេសវៀតណាមហើយក៏ជាច្រកសំខាន់សម្រាប់ជំរុញឱ្យប្រទេសចិនបើកទូលាយចំពោះតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង ។

ប៉ុន្មានឆ្នាំនេះកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចនិងពាណិជ្ជកម្មរវាងប្រទេសចិននិងវៀតណាមបានត្រូវពង្រឹងនិងពង្រីកឥតឈប់ឈរដែលបានបង្កលក្ខណៈងាយស្រួលសម្រាប់ជំរុញការបើកទូលាយ និងការអភិវឌ្ឍសេដ្ឋកិច្ចតាមតំបន់ព្រំដែននៅខេត្តយូនណាន៕

ដោយយ៉ាវ ពីង (ស៊ីនហួ ចិន)

ចិន និងកម្ពុជាបើកជើងហោះហើរអន្តរជាតិថ្មីក្រុងគុនមីង-ក្រុងព្រះសីហនុ

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០១៨ ជើងហោះហើរអន្តរជាតិពីក្រុងគុនមីងទៅក្រុងព្រះសីហនុបានត្រូវបើកជាថ្មី និងបានសាកល្បងហោះហើរដោយជោគជ័យ ។

ជើងហោះហើរថ្មីនេះទទួលបន្ទុកហោះហើរដោយក្រុមហ៊ុនអាកាសចរណ៍យូយលីដែលជាក្រុមហ៊ុនអាកាសចរណ៍របស់ខេត្តយូនណាន។

គួរបញ្ជាក់ថា ក្រុមហ៊ុនអាកាសចរណ៍យូយលីបានរៀបចំឱ្យយន្តហោះរបស់ក្រុមហ៊ុនហោះហើរតាមខ្សែផ្លូវអាកាសចរណ៍ថ្មីនេះនៅរាល់ថ្ងៃពុធ ថ្ងៃសុក្រ និងថ្ងៃអាទិត្យ ដោយចំណាយពេលត្រឹមតែជាង ២ម៉ោងប៉ុណ្ណោះ ។ ក្រៅពីនេះក្រុមហ៊ុនអាកាសចរណ៍យូយ លី នឹងបើកជើងហោះហើរអន្តរជាតិថ្មីពីរទៀតគឺជើងហោះហើរពីស៊ីសាំងប៉ាន់ណាទៅក្រុងឈៀងម៉ៃនិងឈៀងរ៉ាយនៃប្រទេសថៃ ៕

ដោយចាំង តុងឈាំង (ស៊ីនហួចិន)

瑞丽航空 Ruili Airlines
热烈庆祝瑞丽航空首条国际航线"昆明=西哈努克港"首航成功
CONGRATUATION TO RUILI AIRLINES ON THE FIRST INTERNATIONAL FLIGHT BETWEEN KUNMING AND SIHANOUKVILLE

បុគ្គលិកនៃក្រុមហ៊ុនអាកាសចរណ៍ យូយលីអ៊ែរឡាញ ដែលកំពុងតែ ថតរូបជាក្រុម ក្រោយពេល បានចុះចត ដោយជោគជ័យក្រោយការហោះហើរ ពីទីក្រុងគុនមិញ មកកាន់ខេត្តព្រះសីហនុ (រូបថត ដោយ Yang Zhihui)

ក្រុងឈុងឈើងនាំចូលផ្លែឈើប្រទេសអាស៊ីអាគ្នេយ៍តាម "ច្រកផ្លូវទៅភាគខាងត្បូង" លើផ្លូវគោក

ម៉ូហានចំណុចឆ្លងកាត់នៃច្រកព្រំដែនចិន- ឡាវ កំពុងតែក្លាយជាច្រកនាំចូលទំនិញដ៏សំខាន់ពីតំបន់ អាស៊ីអាគ្នេយ៍ ដើម្បីនាំចូលទៅកាន់ ប្រទេសចិន (រូបថតដោយ Zhang Tong)

កុងតឺន័រស្តុកម្សៀនចំនួនពីរមកពីប្រទេសថៃ និងកុងតឺន័រស្តុកស្រកានាគចំនួនពីរមកពីប្រទេសវៀតណាមបានត្រូវដឹកជញ្ជូនទៅដល់កំពង់ផែរួចពន្ធនៃ ក្រុងឈុងឈីងតាម "ច្រកផ្លូវទៅភាគខាងត្បូង" ហើយបានបំពេញបែបបទ ឆ្លងគយដោយជោគជ័យ ។ ផ្លូវនាំចូលផ្លែឈើពីតំបន់អាស៊ីអាគ្នេយ៍តាមផ្លូវគោកថ្មីនេះនឹងអាចសំចៃរយៈពេល២៧ ថ្ងៃ បើប្រៀបធៀបនឹងមធ្យោបាយ ដឹកជញ្ជូនតាមផ្លូវទឹក។

អ្នកទទួលខុសត្រូវនៃកំពង់ផែរួចពន្ធក្រុងឈុងឈីងបានគូសបញ្ជាក់ថា ផ្លែឈើដែលមកពីប្រទេសថៃ និងវៀតណាមទាំងនោះបានត្រូវដឹកជញ្ជូនទៅដល់ក្រុងឈុងឈីងដោយឆ្លងកាត់ច្រកអន្តរជាតម៉ូហាននៃខេត្តយូនណាន ហើយបានចំណាយពេលត្រឹមតែប្រាំបួនថ្ងៃប៉ុណ្ណោះ ។ ផ្លែឈើទាំងនេះបានត្រូវដាក់ក្នុងកុងតឺន័រត្រជាក់ ហើយនិងដឹកជញ្ជូនមកប្រទេសចិន ហើយបានអនុវត្តន៍យន្តការស្តីពីការធ្វើសមាហរណកម្មស្ថាប័នគយទូទាំងប្រទេសចិន ដែលបានទទួលនូវការពិនិត្យតាមដានជាប់រហូតពីស្ថាប័នគយនៃក្រុងឈុងឈីង។ អ្នកជំនាញការបានវិភាគថា "ច្រកផ្លូវទៅភាគខាងត្បូង" ដែលបង្កើតដោយក្រុងឈុងឈីងនោះបានបើកច្រកឡូជីស្ទីកថ្មីមួយសម្រាប់សម្រួលដល់ការនាំចូលផ្លែឈើពីប្រទេសអាស៊ីអាគ្នេយ៍មកក្រុង ឈុងឈីង។

ដោយហួង សៀង(ស៊ីនហួចិន)

បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ីៈ ប្រទេសចិនរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គ

កិច្ចប្រជុំថ្នាក់ដឹកនាំលើកទី៦ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គបានបើកសម័យប្រជុំនៅក្រុងហាណូយនៃប្រទេសវៀតណាម នៅថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៨ ។

លោកយេន ម៉េនឈាំងសមាជិកគណៈកម្មាធិការរៀបចំកិច្ចប្រជុំនិងជាអ្នកទទួលខុសត្រូវនៃផែនការផ្នែកកិច្ចការអាស៊ីអាគ្នេយ៍នៃ ធនាគារ អភិវឌ្ឍន៍អាស៊ីបានថ្លែងថា ក្នុងនាមជាសេដ្ឋកិច្ចធំទី២ លើពិភពលោកប្រទេសចិនបានរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងមហាអនុតំបន់ទន្លេមេគង្គ ។

លោកបានផ្តល់បទសម្ភាសន៍ជាមួយអ្នកសារព័ត៌មានថា ប្រទេសចិនបាន និងកំពុងដើរតួនាទីសំខាន់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គហើយមានឧត្តមភាពពិសេសលើវិស័យទំហំទីផ្សារនិងក្នុងការធ្វើពាណិជ្ជកម្មតាមតំបន់ព្រំដែន ។ ផលិតផលរបស់ប្រទេសផ្សេងៗក្នុងមហាអនុតំបន់ទន្លេមេគង្គនឹងអាចត្រូវបានដឹកជញ្ជូនទៅដល់ខេត្តក្រុងផ្សេងៗនៃប្រទេសចិនដោយឆ្លងកាត់ខេត្តយូនណាននិងក្វាងស៊ី ។ បើគិតបញ្ចូលនូវទីផ្សារចិនទាំងមូលប្រទេសមហាអនុតំបន់ទន្លេមេគង្គអាចទទួលបាននូវទីផ្សារដ៏ធំមួយដែលអាចគ្របដណ្តប់លើប្រជាជន១៦០០ លាននាក់ ។ នេះគឺជាសក្តានុពលដ៏ធំធេងសម្រាប់ជំរុញការធ្វើពាណិជ្ជកម្មអន្តរជាតិ ។

លោកបន្តទៀតថា ក្នុងរយៈពេល២៥ឆ្នាំកន្លងទៅនោះគម្រោងវិនិយោគ ដែលនាំមកដោយយន្តការស្តីពីកិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គបានធ្វើឱ្យសេដ្ឋកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធទទួលបានការរីកចម្រើនយ៉ាងឆាប់រហ័ស ។ លោកបានបញ្ជាក់ទៀតថា ពិតមែនតែកិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គបានទទួលនូវលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ក៏ប៉ុន្តែប្រទេសនានានៅតែប្រឈមនឹងបញ្ហាដ៏ច្រើនដែលមានពាក់ព័ន្ធទៅនឹងវិស័យសំខាន់ចំនួន ៣ រួមមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធការតភ្ជាប់ខ្សែសង្វាក់តម្លៃនិងការធ្វើបដិវត្តន៍ឧស្សាហកម្មលើកទី៤ ។

លោកបានលើកជាមតិថា ប្រទេសមហាអនុតំបន់ទន្លេមេគង្គ និងដៃគូសហប្រតិបត្តិការត្រូវតែផ្តល់អាទិភាពដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដើម្បីដោះស្រាយបញ្ហាប្រឈមផ្សេងៗ ។ សព្វថ្ងៃប្រទេសចិននិងភាគីពាក់ព័ន្ធនានាបានចាត់វិធានការជាក់ស្តែងអំពីការជំរុញការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនតាមផ្លូវដែកដើម្បីសម្រេចបាននូវការតភ្ជាប់គ្នារវាងតំបន់សេដ្ឋកិច្ចពិសេសតាមព្រំដែន និងទីប្រជុំឧស្សាហកម្មព្រមទាំងការតភ្ជាប់គ្នារវាងកំពង់ផែសមុទ្រនិងព្រលានយន្តហោះ ៕

ដោយថាវ ជួន(ស៊ីនហួចិន)

ខេត្តយូនណានចាប់ផ្តើមការសិក្សាស្រាវជ្រាវអំពីសត្វក្ងោកបៃតង

ពេលថ្មីៗនេះរដ្ឋបាលរុក្ខកម្មខេត្តយូនណានបានចាប់ដំណើរការអនុវត្តគម្រោងសិក្សាស្រាវជ្រាវអំពីកន្លែងរស់នៅ និងហ្វូងសត្វក្ងោកបៃតង ។

តាមការឧទ្ទេសនាមពីមន្ទីររុក្ខកម្មខេត្តយូនណានបានឱ្យដឹងថា គម្រោងសិក្សាស្រាវជ្រាវនេះនឹងត្រូវធ្វើឡើងរហូតដល់ចុងខែឧសភា។ ក្រុមជំនាញបានធ្វើដំណើរទៅកាន់ស្រុកចំនួន៥៣ដែលជាកន្លែងអាច មានសត្វក្ងោកបៃតងរស់នៅដើម្បីធ្វើការសិក្សាស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ។

លោកស្រីយ៉ាង សៀវជូនអ្នកជំនាញការមកពីវិទ្យាស្ថានសិក្សាស្រាវជ្រាវសត្វក្រុងគុនមីង នៃបណ្ឌិត្យសភាវិទ្យាសាស្ត្រចិនបានឧទ្ទេសនាមថា សត្វក្ងោកបៃតង គឺជាសត្វព្រៃមួយប្រភេទដែលទទួលបានការអភិរក្សថ្នាក់ជាតិលំដាប់លេខ១ របស់ប្រទេសចិន ។ សត្វប្រភេទនេះបានត្រូវសហព័ន្ធអភិរក្សធម្មជាតិពិភពលោកដាក់បញ្ចូលក្នុងបញ្ជីឈ្មោះនៃសត្វដែលស្ទើរផុតពូជពីព្រោះនៅលើពិភពលោកបច្ចុប្បន្នសល់តែក្ងោកបៃតង២-៣ម៉ឺនក្បាល ។ ក្ងោកបៃតងភាគច្រើនរស់នៅក្នុងតំបន់ព្រៃឈើដែលមានកម្ពស់ទាបជាង២.០០០ម៉ែត្រ នៅតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ជុំវិញ ។ ពួកវាចូលចិត្តរស់នៅលើវាលស្រែឬតំបន់ព្រៃឈើនៅក្បែរទន្លេ ។

តាមរបាយការណ៍មួយដែលប្រកាសដោយវិទ្យាស្ថានសិក្សាស្រាវជ្រាវសត្វក្រុងគុនមីងនៃបណ្ឌិត្យសភាវិទ្យាសាស្ត្រចិននៅឆ្នាំ២០១៦ បានឱ្យដឹងថា នៅក្នុងប្រទេសចិនសត្វក្ងោកបៃតងរស់នៅតែក្នុងស្រុកឬក្រុងចំនួន២២ នៃមណ្ឌលស្វយ័តចំនួនប្រាំបីក្នុងខេត្តយូនណានដែលមានចំនួនតិចជាង ៥០០ ក្បាល៕

ដោយចាវ ជីយ៉ាន (ស៊ីនហួ ចិន)